អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៩

# សេចក្តីប្រកាសព័ត៌មាន

នៅថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៩ អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នឹងចាប់ផ្តើមសវនាការរយៈពេលបីថ្ងៃ នៅក្នុងសំណុំរឿង ០០៣ ប្រឆាំង មាស មុត ។

ជាកិច្ចចាប់ផ្តើម ប្រធានអង្គជំនុំជម្រះនឹងប្រកាសបើកសវនាការជាសាធារណៈ បន្ទាប់មកនឹងមានការអានរបាយការណ៍នៃសំណុំរឿងនេះជាសាធារណៈ ដែលលើកឡើងនូវអង្គហេតុពាក់ព័ន្ធនានា និងប្រវត្តិនីតិវិធីនៃសំណុំរឿង ០០៣ ព្រមទាំងសេចក្តីលម្អិតនៃបណ្តឹងឧទ្ធរណ៍នានាដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ។ សំណៅកោសលុបនៃរបាយការណ៍នេះនឹងអាចរកមើលបាននៅលើគេហទំព័រសាធារណៈរបស់តុលាការ
បន្ទាប់ពីចប់សវនាការនោះភ្លាមៗ។

សវនាការនឹងបន្តដំណើរការនៅថ្ងៃទី ២៨ និងថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៩ តទៅទៀត អនុលោមទៅតាមដីកាកំណត់កាលវិភាគសម្រាប់សវនាការ ដែលបានចេញនៅថ្ងៃទី ២៤ ខែ តុលា ឆ្នាំ២០១៩។ ប្រសិនបើចាំបាច់ ចៅក្រមនឹងតាំងសំណួរដល់ភាគីនានាជាសាធារណៈ នៅថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៩ មុនពេលបញ្ចប់សវនាការ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖
លោក **នេត្រ ភក្ត្រា**
ប្រធានផ្នែកកិច្ចការសាធារណៈនិងជាអ្នកនាំពាក្យ
ទូរសព្ទចល័ត+៨៥៥(0)១២ ៤៨៨ ១៥៦
អ៊ីមែល៖ neth.pheaktra@eccc.gov.kh